ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃ អាទិត្យ ៥ រោច ខែ ជេស្ឋ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២៥

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ខួបគម្រប់ ៥ ឆ្នាំ នៃការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

គិតត្រឹមថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២៥, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធ Online Business Registration Service - OBR) ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការបានរយៈពេល ៥ ឆ្នាំមកហើយ។ ប្រព័ន្ធនេះ បានជួយសម្រួលដល់នីតិវិធីនៃការចុះបញ្ជីអាជីវកម្មរបស់ធុរជន រួមទាំងបានចូលរួមចំណែកក្នុងការលើកកម្ពស់បរិយាកាសធុរកិច្ច និង សេដ្ឋកិច្ចឌីជីថលក្នុងប្រទេសកម្ពុជាផងដែរ។ ប្រព័ន្ធ OBR ក៏បានបន្តពង្រឹង និង ពង្រីកការដ្ឋានជាបន្តបន្ទាប់ ដែលគ្រប-ដណ្តប់ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច (E-Services for Business – ESB) ជាច្រើនទៀត។

ប្រព័ន្ធ OBR ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើកដំបូង កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ជាការចុះបញ្ជីជាខ្សែច្រវ៉ាក់ (Single Portal) ដោយធុរជនអាចស្នើសុំចុះបញ្ជីអាជីវកម្មជាកញ្ចប់រួម មានជាមួយនឹងការចុះបញ្ជីពាណិជ្ជកម្មដោយក្រសួងពាណិជ្ជកម្ម, ការចុះបញ្ជីពន្ធដារដោយអគ្គនាយកដ្ឋានពន្ធដារ និង ការប្រកាសសេចក្តីជូនដំណឹងបើកសហគ្រាសដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈតែម្តង (ហើយកាលពីពាក់កណ្តាលឆ្នាំ ២០២៣ ប្រព័ន្ធបានបន្ថែមការចុះបញ្ជិកាសហគ្រាស-គ្រឹះស្ថានដោយបេឡាជាតិសន្តិសុខសង្គម មួយទៀត)។ ប្រព័ន្ធនេះ បានផ្តល់អត្ថ-ប្រយោជន៍ជាច្រើន ដល់ធុរជន ដោយបានកាត់បន្ថយនីតិវិធី ពេលវេលា និង កម្រៃសេវាមួយចំនួនផងដែរ ហើយអនុញ្ញាតឱ្យអ្នកស្នើសុំ ចុះបញ្ជីអាជីវកម្មបានដោយជោគជ័យក្នុងរយៈពេលត្រឹមតែ ៨ ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើអ្នកស្នើសុំបានផ្តល់ព័ត៌មាន និង ឯកសារភ្ជាប់ត្រឹមត្រូវ និង ពេញលេញ។ បន្ទាប់មកការដ្ឋានរៀបចំប្រព័ន្ធនេះ ត្រូវបានពង្រីកបន្ថែមជាបន្តបន្ទាប់ ដោយគ្របដណ្តប់ដល់ការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតជំនាញ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរហូតមកដល់បច្ចុប្បន្ន មានក្រសួង ស្ថាប័នចំនួន ២១ ចូលរួម និង បានបញ្ចូលសេវាសាធារណៈគោលចំនួន ៣៣ មកក្នុងប្រព័ន្ធអេកូឡូស៊ីនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច។

បន្ថែមពីលើការងារពង្រីកការដ្ឋាន, ប្រព័ន្ធ Single Portal ក៏ត្រូវបានបន្ថែមនូវមុខងារសំខាន់ៗ ជាបន្តបន្ទាប់ ដើម្បីបង្កើនភាពងាយស្រួល និង ទំនុកចិត្ត ដល់អ្នកប្រើប្រាស់។ មុខងារទាំងនោះ រួមមាន៖

- មុខងារចុះបញ្ជីបំពេញបន្ថែមកាតព្វកិច្ច ដែលអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម តែមិនបានចុះបញ្ជីពន្ធដារ ឬ បានចុះបញ្ជីពន្ធដារ តែមិនបានចុះបញ្ជីពាណិជ្ជកម្ម អាចស្នើសុំចុះបញ្ជីពន្ធដារ ឬ ចុះបញ្ជីពាណិជ្ជកម្ម លើប្រព័ន្ធបាន
- មុខងារផ្ទេរសិទ្ធិគ្រប់គ្រងព័ត៌មានក្រុមហ៊ុន/សហគ្រាសពីគណនី CamDigiKey មួយទៅគណនី CamDigiKey មួយទៀត
- មុខងារកែតម្រូវព័ត៌មាន ក្នុងដំណាក់កាលបញ្ជូនត្រលប់ ដែលព័ត៌មានស្នើសុំកែតម្រូវនោះ មិនប៉ះពាល់ដល់ទម្រង់ក្រុមហ៊ុន សហគ្រាស និង/ឬ ការទូទាត់សងប្រាក់ ដែលបានធ្វើឡើងរួចហើយនោះទេ
- មុខងារកែប្រែនាមករណ៍ក្រុមហ៊ុន សហគ្រាស
- មុខងារកែប្រែសកម្មភាពអាជីវកម្ម
- មុខងារកែប្រែព័ត៌មានលម្អិតអាសយដ្ឋានទីស្នាក់ការចុះបញ្ជី
- មុខងារតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ
- មុខងារកែប្រែលក្ខន្តិកៈក្រុមហ៊ុន
- មុខងារកែប្រែព័ត៌មានគណនីធនាគារ
- មុខងារកែប្រែព័ត៌មានលម្អិតអភិបាល
- មុខងារកែប្រែព័ត៌មានលម្អិតម្ចាស់សហគ្រាស
- មុខងារកែប្រែព័ត៌មានលម្អិតម្ចាស់ភាគហ៊ុន
- មុខងារកែប្រែសមាសភាពអ្នកគ្រប់គ្រងសាខា ឬ ការិយាល័យតំណាងក្រុមហ៊ុនបរទេស និង
- មុខងារបញ្ឈប់អាជីវកម្មជាស្ថាពរ សម្រាប់ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម។

សម្រាប់ការងារគាំទ្រ ក្នុងរយៈពេល ៥ ឆ្នាំ នៃការអនុវត្តការងារនេះ, លេខាធិការដ្ឋានក្រុម-ការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច បានសហការយ៉ាងជិតស្និទ្ធជាមួយក្រុម-ការងារជំនាញនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និង ដោះស្រាយបញ្ហាជូនអ្នកប្រើប្រាស់សរុបប្រមាណ ២០ ៧៨៤ ករណី គិតត្រឹមដំណាច់ខែ ឧសភា ឆ្នាំ ២០២៥។ បន្ថែមពីនេះ, លេខាធិការដ្ឋានក៏បានអនុវត្តការងារផ្សព្វផ្សាយជាច្រើន ដោយបានរៀបចំផ្ទាំងផ្សព្វផ្សាយ និង កម្មវិធីឆ្លើយសំនួរប្រចាំសប្តាហ៍ ចំនួន ១ ២៤២, រៀបចំវីដេអូចំនួន ៨១, រៀបចំកិច្ចសម្ភាសន៍ថ្នាក់ដឹកនាំចំនួន ៦ រូប, រៀបចំកិច្ចសម្ភាសន៍ម្ចាស់អាជីវកម្មចំនួន ៦ រូប, រៀបចំ និង ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និង ពិគ្រោះយោបល់ ចំនួន ៨៧, រៀបចំកម្មវិធីជជែកវែកញែក "ពីនេះពីនោះរឿងស្នើសុំធ្វើអាជីវកម្ម" រដូវកាលទី ១ និង រដូវកាលទី ២ ដោយផ្សាយផ្ទាល់ចំនួន ២០ វគ្គ, កែសម្រួល និង បន្ថែមខ្លឹមសារលើថ្នាលធុរកិច្ច (business.gov.kh) និង បានបោះពុម្ពព្រឹត្តិបត្រប្រចាំឆ្នាំ ២០២២, ២០២៣ និង ២០២៤ សម្រាប់ផ្សព្វផ្សាយពីវឌ្ឍនភាពការងារក្នុងមួយឆ្នាំៗ និង បានចែកចាយទៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាធារណជន ផងដែរ។

លើសពីនេះទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ឱ្យអនុវត្តជាផ្លូវការនូវ "យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍ

សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨" កាលពីខែ មេសា ឆ្នាំ ២០២៥ ថ្មីៗនេះ ក្នុងគោលបំណង "បង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក សំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និង លើកកម្ពស់ការបំពេញអនុលោមភាព"។

ក្នុងឱកាសអបអរសាទរខួបគម្រប់ ៥ ឆ្នាំនៃការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, លេខាធិការដ្ឋានសូមផ្តល់ជូននូវវឌ្ឍនភាពការងារជាតួលេខគិតត្រឹមថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៥ ដូចខាងក្រោម ៖

១. ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច)

| បរិយាយ | ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៥ |
|---|---|
| ចំនួនពាក្យស្នើសុំចុះបញ្ជីអាជីវកម្មអនុម័តសរុប | 46 776 |
| ម្ចាស់អាជីវកម្មដែលជាស្ត្រី | 17 240<br>(~37% នៃចំនួនសរុប) |
| ទំហំដើមទុនចុះបញ្ជីសរុប | ~74.72 ទ្រីលានរៀល<br>(~18.23 ប៊ីលានដុល្លារអាមេរិក[1]) |
| ពាក្យស្នើសុំបម្រុងទុកនាមករណ៍អនុម័តសរុប | 23 786 |
| ចំនួនអាជ្ញាបណ្ណ លិខិតអនុញ្ញាត និង វិញ្ញាបនបត្រ និងឯកសារពាក់ព័ន្ធផ្អែកលើសកម្មភាពអាជីវកម្មតាមវិស័យ | 51 372 |

២. កម្មវត្ថុអាជីវកម្ម ៥ ដែលទទួលបានទុនវិនិយោគច្រើនជាងគេ

| ល.រ. | បរិយាយ | ដើមទុនចុះបញ្ជីសរុប<br>(១ ដុល្លារអាមេរិក = ៤១០០ រៀល) | ដើមទុនគិតជា % |
|---|---|---|---|
| ១ | សកម្មភាពសេវាកម្មស្នាក់នៅ | ~6.38 ទ្រីលានរៀល<br>(~1.56 ប៊ីលានដុល្លារអាមេរិក) | 8.54% |
| ២ | សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬ ជួលពីគេ | ~6.00 ទ្រីលានរៀល<br>(~1.46 ប៊ីលានដុល្លារអាមេរិក) | 8.02% |
| ៣ | ការសាងសង់អាគារ | ~5.84 ទ្រីលានរៀល<br>(~1.42 ប៊ីលានដុល្លារអាមេរិក) | 7.82% |
| ៤ | កម្មន្តសាលសម្លៀកបំពាក់ លើកលែងសម្លៀកបំពាក់ធ្វើពីរោមសត្វ | ~3.66 ទ្រីលានរៀល<br>(~892 លានដុល្លារអាមេរិក) | 4.90% |
| ៥ | សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង | ~3.63 ទ្រីលានរៀល<br>(~884 លានដុល្លារអាមេរិក) | 4.85% |
| ៦ | កម្មវត្ថុអាជីវកម្មផ្សេងទៀត | ~49.22 ទ្រីលានរៀល<br>(~12.01 ប៊ីលានដុល្លារអាមេរិក) | 65.88% |

[1] អត្រាប្តូរប្រាក់ ១ ដុល្លារអាមេរិក=៤,១០០ រៀល

៣. កម្មវត្ថុអាជីវកម្មទាំង ៥ ដែលមានក្រុមហ៊ុន/សហគ្រាសទទួលបានការចុះបញ្ជីច្រើនជាងគេ

| ល.រ. | បរិយាយ | ចំនួនក្រុមហ៊ុន សហគ្រាស | ដើមទុនគិតជា % |
|---|---|---|---|
| ១ | សកម្មភាពសេវាកម្មភោជនីយដ្ឋាន និង សេវាកម្មផ្គត់ផ្គង់អាហារចល័ត | 4130 | 8.83% |
| ២ | ការលក់ដុំឯកទេសផ្សេងៗ | 2672 | 5.71% |
| ៣ | ការលក់ដុំទំនិញប្រើប្រាស់ក្នុងផ្ទះ | 2336 | 4.99% |
| ៤ | ការលក់រាយទំនិញផ្សេងៗទៀតនៅក្នុងហាងឯកទេស | 1858 | 3.97% |
| ៥ | ការសាងសង់អាគារ | 1837 | 3.93% |
| ៦ | កម្មវត្ថុអាជីវកម្មផ្សេងទៀត | 33949 | 72.57% |

សមិទ្ធផលទាំងនេះ សរបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែង និង ការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាការចូលរួមផ្តល់យោបល់ពីវិស័យឯកជន រួមជាមួយនឹង ការគាំទ្រយ៉ាងពេញទំហឹង និង ការដឹកនាំប្រកបដោយចក្ខុវិស័យដ៏មុតស្រួចរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

CamDX